*រាជធានីភ្នំពេញ ថ្ងៃសុក្រ ១រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*ត្រូវនឹងថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២*

# សេចក្តីថ្លែងការណ៍រួម
# ក្រុមអង្គការសង្គមស៊ីវិល សំណូមពររាជរដ្ឋាភិបាល ឱ្យចាត់វិធានការចាំបាច់ដើម្បីអនុវត្ត អនុសាសន៍របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ី-ដ

នាឱកាសយុទ្ធនាការ ១៦ ថ្ងៃ និងទិវាសិទ្ធិមនុស្សអន្តរជាតិ ឆ្នាំ ២០២២ យើងខ្ញុំតំណាងឱ្យក្រុមអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សមាគម សហជីព ដូចមានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលដាក់ចេញនូវជំហានជាក់លាក់ ដើម្បីអនុវត្តអនុសាសន៍ដែលបានចែងនៅក្នុងសេចក្តីអង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈ កម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ី-ដ (គណៈកម្មាធិការស៊ី-ដ) ដើម្បីលើកកម្ពស់សិទ្ធិមនុស្សរបស់ស្ត្រីនៅកម្ពុជា ។

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW) និងអង្គការសង្គមស៊ីវិលជាដៃគូ កំពុងចេញផ្សាយនូវរបាយការណ៍តាមដានការអនុវត្តអនុសញ្ញាស៊ី-ដ សម្រាប់ឆ្នាំ២០២១ ។ របាយការណ៍នេះបានលើកយកនូវចំណុចជោគជ័យ និងបញ្ហាខ្វះចន្លោះរបស់រាជរដ្ឋាភិបាល ចំពោះការអនុវត្តអនុសញ្ញាលុបបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (អនុសញ្ញាស៊ី-ដ) ក្នុងអំឡុងឆ្នាំ២០២១ ។ របាយការណ៍នេះផងដែរ ក៏បានរំលេចឡើងនូវវឌ្ឍនភាពស្តីពីជំហាននានាក្នុងការអនុវត្តអនុសាសន៍ ដែលមានចែងនៅក្នុងសេចក្តីអង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការ ឆ្នាំ២០១៩ ទៅតាមការពិនិត្យ ការអនុវត្តអនុសញ្ញា របស់រាជរដ្ឋាភិបាល ។

យើងខ្ញុំទាំងអស់គ្នាសូមធ្វើការសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជាមេត្តាដាក់ចេញជាជំហានចាំបាច់ ដើម្បីឆ្ពោះទៅរកភាពជោគជ័យក្នុងការអនុវត្តសេចក្តីអង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការស៊ី-ដ និងការធានាថាគ្រប់ស្ត្រី និងអ្នកដែលមិនកំណត់អត្តសញ្ញាណយេនឌ័រទាំងអស់ទទួលបានយ៉ាងពេញលេញនូវសិទ្ធិមនុស្សរបស់ពួកគេ ។

១) យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលសូមបង្កើតច្បាប់ប្រឆាំងនឹងការរើសអើងដែលមានលក្ខណៈពេញលេញដោយធានាឱ្យមានយន្តការច្បាប់មួយសម្រាប់អនុវត្តនូវសិទ្ធិរបស់ស្ត្រីនៅក្នុងរដ្ឋធម្មនុញ្ញ និងអនុសញ្ញាស៊ី-ដ និងលុបចោលនូវរាល់មាត្រាទាំងអស់នៅក្នុងច្បាប់ ដែលចូលជាធរមានដែលមិនស្របគ្នាទៅនឹងសិទ្ធិទាំងនោះ ។ យើងខ្ញុំសូមសំណូមពរដល់រដ្ឋាភិបាលឱ្យដំណើរការការសិក្សាវិភាគជាប្រចាំអំពីយេនឌ័រនៅគ្រប់សេចក្តីព្រាងច្បាប់ ឬគោលនយោបាយនានា ។

២) យើងខ្ញុំទាំងអស់គ្នានៅតែបន្តអំពាវនាវ សូមឱ្យមានការបម្រុងថវិកាជំនួយរយៈពេលវែងចេញពីថវិកាជាតិសម្រាប់អនុវត្តការងារបញ្ជ្រាបយេនឌ័រ ប្រយោជន៍បង្កើនសមភាពយេនឌ័រលើគ្រប់វិស័យ ។

៣) យើងខ្ញុំសូមសំណូមពរឱ្យមានកិច្ចប្រឹងប្រែងជាក់លាក់ ដើម្បីប្រយុទ្ធប្រឆាំងនឹងផ្នត់គំនិតដែលថាការសម្រុះសម្រួលក្នុងករណីនៃអំពើហិង្សាលើដៃគូស្និទ្ធស្នាល គឺជាលទ្ធផលដែលសមស្រប ។ រាជរដ្ឋាភិបាលចាំបាច់គួរតែធ្វើសកម្មភាពច្បាស់លាស់ក្នុងការធ្វើវិសោធនកម្ម និងពង្រឹងច្បាប់ស្តីពី « ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ » ដើម្បីឆ្លុះបញ្ចាំងថាសិទ្ធិនៃអ្នកនៅរស់រានជីវិតពីអំពើហិង្សាស្របតាមទៅតាមជម្រើសរបស់ពួកគេក្នុងការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ ។

៤) យើងខ្ញុំនៅតែបន្តទទូចស្នើដល់រាជរដ្ឋាភិបាល សូមឱ្យផ្តល់សច្ចាប័នលើអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិខាងផ្នែកការងារ លេខ ១៩០ ស្តីពី « ការលុបបំបាត់អំពើហិង្សា និងការបៀតបៀនក្នុងពិភពការងារ » និងផ្តល់និយមន័យឱ្យច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ និងផ្តល់ការដោះស្រាយសម្រាប់គ្រប់ទម្រង់នៃការបៀតបៀន ។

៥) យើងខ្ញុំបន្តសំណូមពរដល់រាជរដ្ឋាភិបាល សូមបណ្តុះបណ្តាលដល់ភ្នាក់ងារសន្តិសុខទាំងអស់ដែលគាំទ្រដោយរដ្ឋ ឬរដ្ឋបាលរាជធានី ខេត្ត រួមមានអ្នកគ្រប់គ្រង និងអ្នកចាត់ចែងផ្ទាល់របស់ពួកគេអំពីរបៀបនៃការប្រាស្រ័យទាក់ទងជាមួយសាធារណជន និងជាពិសេសស្ត្រីក្រុមអ្នកតវ៉ា និងសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ តាមបែបអហិង្សា និងប្រកបដោយឥរិយាបថគិតគូរអំពីយេនឌ័រ និងឱ្យបុគ្គលដែលរងការចោទប្រកាន់ពីបទប្រព្រឹត្តហិង្សា និងបៀតបៀនទទួលខុសត្រូវចំពោះទង្វើរបស់ ពួកគេ ។

៦) យើងខ្ញុំសំណូមពរដល់រាជរដ្ឋាភិបាល សូមឱ្យផ្តល់ធនធានថវិកាជាតិដើម្បីធានាថាស្ត្រី និងអ្នកដែលមិនកំណត់អត្តសញ្ញាណយេនឌ័រទទួលបានការថែទាំសុខភាពផ្លូវភេទ និងសុខភាពបន្តពូជបានត្រឹមត្រូវ រួមមានការថែទាំសុខភាពមុនពេលសម្រាល និងយុទ្ធនាការចាក់វ៉ាក់សាំងដល់ស្ត្រីមានផ្ទៃពោះទាំងអស់ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និងទារក ៕

**សម្រាប់ព័ត៌មានលម្អិត សូមទំនាក់ទំនងមកកាន់៖**


- អ្នកស្រី ជឹម ចាន់នាង, អគ្គលេខាធិការអង្គការ NGO-CEDAW, ទូរសព្ទ 012 668 853
- អ្នកស្រី បុណ្យ រចនា, នាយិកាប្រតិបត្តិអង្គការក្លាហាន, ទូរសព្ទ 089 476 146


**សេចក្តីថ្លែងការណ៍រួមនេះគាំទ្រដោយ៖**

១. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)

២. សមាគមគាំពារស្ត្រីងាយរងគ្រោះ (ASVW)

៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)

៤. សហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា (CFSWF)

៥. សហភាពការងារកម្ពុជា(CLC)

៦. អង្គការកម្ពុជាដើម្បីសុខភាព និងការអប់រំសហគមន៍ (CHEC)

៧. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិនុស្ស លីកាដូ (LICADHO)

៨. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

៩. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)

១០. សមាគមប្រជាធិបតេយ្យឯករាជ្យ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

១១. អង្គការក្លាហាន (Klahaan)

១២. គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ (NICFEC)

១៣. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រី (NGO-CEDAW)

១៤. សមាគមថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)

១៥. អង្គការមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់)

១៦. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)

១៧. មណ្ឌលព័ត៌មានស្ត្រីកម្ពុជា (WMC)